**ឧបសម្ព័ន្ធ I**

# គោលការណ៍ និងលក្ខខណ្ឌនៃការតាំងពិព័រណ៌

## ១. អ្នករៀបចំកម្មវិធី

ពិព័រណ៍ឧស្សាហកម្មសំណង់កម្ពុជា អន្តរជាតិ គឺត្រូវបានរៀបចំដោយសមាគមអ្នកសាងសង់កម្ពុជា(ស.ស.ក) ដែលក្នុងកិច្ចព្រមព្រៀងនេះហៅថា "អ្នករៀបចំ"។ សិទ្ធិ អំណាច និងឆន្ទានុសិទ្ធិទាំងអស់ដែលអនុវត្តក្រោមកិច្ចព្រមព្រៀងនេះ ត្រូវអនុវត្តក្នុងនាមជាភ្នាក់ងារតំណាងឱ្យអ្នករៀបចំកម្មវិធី។ អ្នករៀបចំ និងអ្នកតាំងពិព័រណ៍ ត្រូវហៅជារួមថាជា "ភាគី" ហើយពួកគេម្នាក់ៗហៅថា "ភាគី"។ អ្នកម៉ៅការសេវាកម្មតាំងពិព័រណ៍ផ្លូវការគឺ សមាគមអ្នកសាងសង់កម្ពុជា។ សេវាកម្មទាំងអស់ដែលតម្រូវដោយអ្នកតាំងពិព័រណ៍នឹងអាចរកបានតាមរយៈ អ្នករៀបចំ អ្នកម៉ៅការ និងភ្នាក់ងាររបស់សមាគម។ គ្មានអ្នកម៉ៅការផ្សេងទៀតនឹងត្រូវបានអនុញ្ញាតដោយគ្មានការយល់ព្រមជាមុនទេ។ តុសេវាកម្មនឹងត្រូវបានរក្សាទុកនៅក្នុងតំបន់តាំងពិពណ៌។ ភ្នាក់ងារជួយលក់ស្តង់ ត្រូវមានការស្នើសុំ និងមានការអនុញ្ញាតឱ្យធ្វើជាភ្នាក់ងារជួយលក់ ឬជួលស្តង់ ពីភាគី**អ្នករៀបចំកម្មវិធី**ជាមុនទើបអាចធ្វើសកម្មភាពជួលស្តង់ឬកន្លែងសម្រាប់ដាក់តាំងបង្ហាញផលិតផលបន្តឱ្យជនទីបី (អ្នកដាក់តាំងពិព័រណ៍ ) ដែលបានចុះហត្ថលេខាក្នុងកិច្ចសន្យាជាមួយខ្លួនបាន ហើយកិច្ចសន្យាដែលចុះដោយភ្នាក់ងារជួយលក់ស្តង់ ជាមួយអ្នកដាក់តាំងពិព័រណ៍នេះ មិនស្ថិតក្នុងការទទួលខុសត្រូវ របស់ភាគីអ្នករៀបចំកម្មវិធីទេ ។

## ២. កាលបរិច្ឆេទ និងរយៈពេល នៃការតាំងពិព័រណ៍

អ្នកតាំងពិព័រណ៍ត្រូវទទួលស្គាល់ថា អ្នករៀបចំកម្មវិធីមានសិទ្ធិក្នុងការសម្រេចចិត្តជាដាច់ខាតរបស់ខ្លួនក្នុងការផ្លាស់ប្តូរ ឬពន្យារពេលកាលបរិច្ឆេទ ឬរយៈពេលនៃការតាំងពិព័រណ៍នៅពេលណាក៏បាន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកតាំងពិព័រណ៍រយៈពេល ១០ ថ្ងៃ ។ ដោយមិនទទួលខុសត្រូវ ការខូចខាត ឬទាមទារអ្វីពីអ្នកតាំងពិព័រណ៍ណាមួយឡើយ និងក៏មិនមានការបង្វិលសងនៃចំនួនប្រាក់កក់ ប្រាក់ដែលបានទូទាត់ហើយ ឬការទូទាត់ដោយផ្នែកណាមួយ ត្រូវផ្តល់ទៅឱ្យអ្នកតាំងពិព័រណ៍សម្រាប់ការផ្លាស់ប្តូរ ឬការពន្យារពេលណាមួយនៅក្នុងកាលបរិច្ឆេទ ឬរយៈពេលនៃការតាំងពិព័រណ៍ ស្របតាមប្រការនេះឡើយ។ ស្តង់ទាំងអស់ត្រូវបើក និងអនុញ្ញាតឱ្យបុគ្គលិកចូលបម្រើការងារក្នុងអំឡុងថេរវេលាដូចខាងក្រោម÷

- ថ្ងៃដំបូង ( ថ្ងៃសម្ពោធពិធី ) ចាប់ពីម៉ោង ០៧ : ០០ ព្រឹក ដល់ម៉ោង ០៧ : ០០ ល្ងាច
- ថ្ងៃបន្ទាប់ ( ថ្ងៃទី២ និងថ្ងៃទី៣) ពីម៉ោង ០៨ : ០០ ព្រឹក ដល់ម៉ោង ០៧ : ០០ ល្ងាច

## ៣. សម្ភារៈមាននៅក្នុងស្តង់ជួល




ភាគីអ្នករៀបចំកម្មវិធីនឹងផ្គត់ផ្គង់សម្ភារៈដូចខាងក្រោម ÷

- **<u>ស្តង់:</u>** ទំហំ ៣ម x ៣ម នឹងរួមបញ្ចូលៈកំរាលព្រំ ៣ម x ៣ម
- អំពូលម៉ែត ( ៤០ វាត់ ) ចំនួន ២
- ឌុយភ្លើង ( ៥ អំពែរ ២២០វ៉ុល ) ចំនួន ១
- តុព័ត៌មាន ចំនួន ១ នឹងកៅអី ចំនួន ២
- ធុងសំរាម ចំនួន ១
- បន្ទះក្តារពណ៌សសម្រាប់បាំងជញ្ជាំងខាងក្រោយ និងជញ្ជាំងសងខាង និងបន្ទះក្តារខាងលើមានបិទឈ្មោះក្រុមហ៊ុន ។

-

*ក្នុងករណីអ្នកដាក់តាំងពិព័រណ៍ត្រូវការសម្ភារ និងឧបករណ៍ផ្សេងៗសម្រាប់ការតម្លើង និងតុបតែងក្រៅអំពីសម្ភារដែលបានផ្តល់ជូនខាងលើគឺអ្នកដាក់តាំងពិព័រណ៍ជាអ្នកទទួលខុសត្រូវដោយខ្លួនឯង។ក្នុងករណីភាគីអ្នករៀបចំកម្មវិធីជួយស្វែងរកជូន នោះការចំណាយជាបន្ទុកផ្ទាល់របស់អ្នកដាក់តាំងពិព័រណ៍ ។

## ៤. ការបង់ប្រាក់ថ្លៃជួលស្តង់

កិច្ចសន្យាជួលស្តង់អាចចុះហត្ថលេខាបាន បន្ទាប់ពីសមាគមអ្នកសាងសង់កម្ពុជាបានធ្វើការផ្សព្វផ្សាយស្តីអំពីការតាំងពិព័រណ៍ឧស្សាហកម្មសំណង់កម្ពុជា អន្តរជាតិ ជាសាធារណៈ។ នៅពេលចុះហត្ថលេខាលើកិច្ចសន្យា នោះអ្នកដាក់តាំងពិព័រណ៍ត្រូវបង់ប្រាក់កក់ចំនួន ៥០% នៃប្រាក់ជួលស្តង់សរុប។ ប្រាក់ដែលនៅសល់ចំនួន ៥០% នឹងតម្រូវឱ្យបង់ផ្តាច់ និងមិនអាចឱ្យយឺតជាង៣ខែមុន( នៅខែកញ្ញា )កម្មវិធីប្រព្រឹត្តឡើង ។ សម្រាប់អ្នកតាំងពិព័រណ៍ជាក្រុមហ៊ុនក្រៅប្រទេស ការបង់ប្រាក់តែ១ដង នៅពេលដែលចុះកិច្ចសន្យាកក់ស្តង់ ការទូទាត់ប្រាក់អាចធ្វើតាមរយៈផ្តល់ជា សែក សាច់ប្រាក់ ឬការផ្ទេរប្រាក់ទៅគណនីរបស់សមាគមអ្នកសាងសង់កម្ពុជាតាមធនាគារកាណាឌីយ៉ាលេខ: ០០១ ០០០ ១៨៨ ១១១១។ ការទូទាត់ប្រាក់ ទាំងប្រាក់កក់ និងប្រាក់ដែលនៅសល់គឺត្រូវបានចាត់ទុកថារួចរាល់បន្ទាប់ពីអ្នករៀបចំកម្មវិធីបានចេញវិក័យបត្រទៅឱ្យអ្នកចូលរួមដាក់តាំងពិព័រណ៍រួច ។

## ៥. ការប្រើប្រាស់ទីតាំង

ការកំណត់ទីធ្លាដែលបានផ្តល់ឱ្យ ស្ថិតនៅក្នុងការសម្រេចចិត្តតែមួយគត់របស់អ្នករៀបចំដែលជាអ្នកធ្វើការសម្រេចចុងក្រោយ។អ្នករៀបចំអាចពីពេលមួយទៅពេលមួយធ្វើការផ្លាស់ប្តូរទីធ្លា ដែលបានកំណត់ឱ្យទៅទីធ្លាមួយទៀតដែលមានទំហំស្មើគ្នាដោយជម្រាបជូនអ្នកតាំងពិព័រណ៍នូវសេចក្តីជូនដំណឹង៣ថ្ងៃមុនជាលាយលក្ខណ៍អក្សរនៃការផ្លាស់ប្តូរ។ លក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះត្រូវមានអនុភាពចំពោះទីតាំងដែលពាក់ព័ន្ធខាងលើនិងការកំណត់រួចដោយអ្នករៀបចំកម្ម។ ខ្នាតទំហំដែលបានដាក់បង្ហាញនៅលើប្លង់ទីតាំងនៃសាលតាំងពិព័រណ៍យ៉ាងត្រឹមត្រូវតាមអ្វីដែលអាចធ្វើទៅបាន ប៉ុន្តែការគ្រប់គ្រងសូមរក្សាសិទ្ធិគ្រប់ពេលវេលាសម្រាប់កែប្រែប្លង់បាតដើម្បីបំពេញតម្រូវការរបស់ការតាំងពិព័រណ៍ និងអ្នកតាំងពិព័រណ៍។រាល់ការធ្វើបទបង្ហាញពន្យល់ សម្ភាសន៍ ការចែកចាយខិតប័ណ្ណការលក់ ឬសកម្មភាពផ្សព្វផ្សាយដ៏ទៃទៀតទាំងអស់ត្រូវតែស្ថិតនៅក្នុងទីធ្លាដែលខ្លួនបានជួល។ អ្នកតាំងពិព័រណ៍ម្នាក់ៗត្រូវទទួលខុសសម្រាប់ការរក្សាច្រកផ្លូវ ឬច្រកនៅក្បែរចំហៀងស្តង់ឱ្យស្ថិតក្នុងភាពទំនេរ អត់មានការកកស្ទះក្នុងអំឡុងពេលធ្វើបទបង្ហាញ ឬការផ្សព្វផ្សាយផ្សេងៗ។អ្នកតាំងពិព័រណ៍គឺត្រូវបានហាមឃាត់ពីការព្យួរផ្ទាំងបដាលើពិដានដោយពុំមានបង់ប្រាក់ទៅឱ្យអ្នករៀបចំកម្មវិធីអំពីការផ្សព្វផ្សាយដែលពាក់ព័ន្ធរបស់ខ្លួន។ គ្មានអ្នកតាំងពិព័រណ៍ណាម្នាក់អាចចាត់ចែង បញ្ជូនបន្ត ឬចែករំលែកកន្លែងដែលបានបែងចែកដោយគ្មានការដឹងឮនិងការយល់ព្រមពីអ្នកគ្រប់គ្រងកម្មវិធីឡើយ។ គ្មានក្រុមហ៊ុនឬអង្គការឬភ្នាក់ងារណាមួយដែលត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មនៅក្នុងតំបន់តាំងពិព័រណ៍នោះទេ ប្រសិនបើមិនបានចុះហត្ថលេខាលើកិច្ចសន្យាដើម្បីចាត់តាំងកន្លែងតាំងពិព័រណ៍ជាមួយអ្នករៀបចំពិព័រណ៍។

## ៦. ពេលវេលានៃការតម្លើង និងរុះរើស្តង់របស់អ្នកតាំងពិព័រណ៍

ជាការព្រមព្រៀងទាំងសងខាងថា ក្នុងករណីដែលអ្នកតាំងពិព័រណ៍ជួលស្តង់ពីអ្នករៀបចំកម្មវិធីគឺជាភារកិច្ច និងការទទួលខុសត្រូវរបស់អ្នករៀបចំកម្មវិធីក្នុងការតំឡើងស្តង់នៅមុនពេលបើកការតាំងពិព័រណ៍ នឹងរុះរើស្តង់បន្ទាប់ពីកម្មវិធីត្រូវបានបញ្ចប់ ហើយការចំណាយជាបន្ទុកផ្ទាល់របស់អ្នករៀបចំកម្មវិធី។ ក្នុងករណីអ្នកតាំងពិព័រណ៍ ជួលតែទីធ្លានោះ ការតុបតែងស្តង់ ឬការងារភ្ជាប់តម្លើង និងរុះរើគឺជាការទទួលខុសត្រូវផ្ទាល់របស់អ្នកតាំងពិព័រណ៍។ ការជ្រៀតជ្រែកយកអគ្គិសនី ព្រី អំពូល និងទីធ្លារបស់អ្នកតាំងពិព័រណ៍ដទៃគឺត្រូវបានហាមឃាត់ ។

### ក. ការរៀបចំស្តង់ និងទីកន្លែង

ការតម្លើងស្តង់ទាំងអស់អាចចាប់ផ្តើមចូលរៀបចំ៣ថ្ងៃមុនកម្មវិធីមកដល់ ហើយត្រូវតម្លើងឱ្យចប់សព្វគ្រប់រួចរាល់មុន១ថ្ងៃនៃកម្មវិធីមកដល់នៅម៉ោង ០៥ : ០០ ល្ងាច ។

### ខ. ការរុះរើស្តង់

ស្តង់ត្រូវតែរុះរើចេញពីសាលតាំងពិព័រណ៍មិនឱ្យយឺតជាងម៉ោង ០៥ :០០ ល្ងាច នៃថ្ងៃបន្ទាប់ពីថ្ងៃចុងក្រោយនៃកម្មវិធី ។ប្រសិនស្តង់មិនបានរុះរើក្នុងពេលវេលានេះទេ នោះអ្នករៀបចំកម្មវិធីនឹងធ្វើការរុះរើស្តង់ និងយកសម្ភារៈដែលនៅសល់ក្នុងស្តង់ទៅទុកនៅក្នុងឃ្លាំងកន្លែងណាមួយ ហើយអ្នកតាំងពិព័រណ៍ត្រូវចំណាយចំពោះករណីនេះ។ការរុះរើមុនពេលគឺជាការរំខានដល់ការបង្ហាញការតាំងពិព័រណ៍ ហេតុនេះអ្នកតាំងពិព័រណ៍មិនត្រូវវេចខ្ចប់ ឬរុះរើផ្នែកណាមួយនៃពិព័រណ៍ មុនពេលវេលានៃការបិទ ឬបញ្ចប់កម្មវិធីជាផ្លូវការនូវម៉ោង ០៧ :០០ ល្ងាច នៃថ្ងៃចុងក្រោយនៃកម្មវិធីឡើយ។ ក្នុងករណីបន្ទាន់ខ្លាំង និងមិនអាចរង់ចាំដល់ពេលវេលានៃការបញ្ចប់កម្មវិធីបាន អ្នកតាំងពិព័រណ៍ត្រូវសរសេរស្នើសុំការអនុញ្ញាតការរុះរើពីអ្នករៀបចំកម្មវិធី ហើយទាល់មានការអនុញ្ញាតរួចហើយទើបអ្នកតាំងពិព័រណ៍អាចរុះរើបាន។ អ្នកតាំងពិព័រណ៍អាចរើស្តង់ និងយកសម្ភារៈពួកគេចេញនៅថ្ងៃចុងក្រោយនៃកម្មវិធីតាំងពិព័រណ៍ចាប់ពីម៉ោង៧ : ៣០ រហូតដល់ម៉ោង ៩ : ៣០ យប់។ បន្ទាប់ពីម៉ោង ៩ : ៣០ យប់ ដំណើរការរុះរើត្រូវបានបញ្ឈប់ ហើយនឹងអនុញ្ញាតឱ្យចាប់ផ្តើមបន្តការរុះរើនូវម៉ោង ០៨ : ០០ ព្រឹក នៃថ្ងៃបន្ទាប់ ។

### គ. ការជួលក្រុមហ៊ុនតម្លើង និងតុបតែងស្តង់មកពីខាងក្រៅ

រាល់ការតម្លើងស្តង់ក្នុងកម្មវិធីតាំងពិព័រណ៍ឧស្សាហកម្មសំណង់កម្ពុជា-អន្តរជាតិ ជាកម្មសិទ្ធិរបស់សមាគមអ្នកសាងសង់កម្ពុជា។ ក្នុងករណីអ្នកជួលស្តង់បានជួលតែទីធ្លា ហើយមានបំណង ចង់ជ្រើសរើសក្រុមហ៊ុនក្រៅមកតម្លើង និងតុបតែងស្តង់របស់ខ្លួននោះត្រូវមកធ្វើការទំនាក់ទំនង និងស្នើសុំការអនុញ្ញាតពីអ្នករៀបចំកម្មវិធីឱ្យបានមុនពេលកម្មវិធីមកដល់ចំនួន៦០ថ្ងៃ ។

## ៧. ការថែទាំអគារ និងគ្រឿងបរិក្ខារ

អ្នកតាំងពិព័រណ៍ ឬភ្នាក់ងាររបស់ពួកគេ មិនត្រូវធ្វើប៉ះពាល់ ឬខូចខាតជញ្ជាំង ឬកម្រាលឥដ្ឋរបស់អគារព្រមទាំងស្តង់ ឬគ្រឿងបរិក្ខាររបស់ស្តង់ឡើយ។ មិនត្រូវបិទលើ ដំជាប់ ដំដែកគោល ស្វាន ឬក៏ភ្ជាប់នឹងសសរ

ជញ្ជាំង កម្រាលឥដ្ឋ ឬក៏ផ្នែកផ្សេងៗនៃអគារ ឬគ្រឿងសង្ហារឹម។ការបិទពង្រាយ ស្ទិចគ័រផ្សព្វផ្សាយ ឬស្លាកសញ្ញាគឺត្រូវបានហាមឃាត់ជាដាច់ខាត។ នៅពេលមានការខូចខាតកើតឡើង អ្នកតាំងពិព័រណ៍គឺជាអ្នកទទួលខុសត្រូវចំពោះមុខម្ចាស់នៃទ្រព្យដែលបានខូចខាតនោះ។ សម្ភារៈដែលបានប្រើប្រាស់ទាំងអស់នៅក្នុងការតុបតែងត្រូវមានការការពារពីអណ្តាតភ្លើង។ សម្ភារៈចំហេះ ឬគ្រឿងផ្ទុះមិនត្រូវបានអនុញ្ញាតឱ្យមាននៅក្នុងសាលពិព័រណ៍ ។

## ៨. បណ្ណចូល

អ្នកតាំងពិព័រណ៍ត្រូវផ្ញើរបញ្ជីឈ្មោះនៃអ្នកតំណាង(បុគ្គលិក)ដែលពាក់ព័ន្ធជាមួយនឹងការតាំងពិព័រណ៍របស់ខ្លួនឱ្យទៅអ្នករៀបចំកម្មវិធី ដើម្បីឱ្យអ្នករៀបចំកម្មវិធីផ្តល់ប័ណ្ណចូលក្នុងសាលតាំងពិព័រណ៍ក្នុងអំឡុងពេលនៃកម្មវិធីជូនដល់ពួកគេ។ បញ្ជីឈ្មោះត្រូវផ្ញើរជូនក្នុងរយៈពេលបួនសប្តាហ៍មុនកម្មវិធីចាប់ផ្តើម ។

## ៩. ការធ្វើការលុបចោល

រាល់ការធ្វើការលុបចោល ឬបញ្ឈប់កិច្ចសន្យាត្រូវធ្វើជាលាយល័ក្ខអក្សរ។ ប្រសិនការលុបចោលកិច្ចសន្យាដោយខ្លួនឯង ( អ្នកជួលស្តង់ ) ឬការបញ្ឈប់កិច្ចសន្យាដែលបណ្តាលមកពីបញ្ហាផ្សេងៗដែលធ្វើឱ្យប៉ះពាល់ដល់កម្មវិធី ដោយអ្នកជួលស្តង់ គឺមិនអាចបង្វិលប្រាក់ជូនវិញបានឡើយ។ តែប្រសិនមានករណីមានប្រធានសក្តិ ឬមិនមានសុវត្ថិភាព ឬអសន្តិសុខដែលប៉ះពាល់ដល់កម្មវិធីនិងមិនអាចធ្វើឱ្យកម្មវិធីដំណើរការបាននោះ អ្នករៀបចំកម្មវិធីត្រូវធ្វើការបង្វិលប្រាក់កក់ទាំងអស់សងទៅឱ្យអ្នកជួលស្តង់វិញគ្រប់ចំនួនដែលបានបង់ ។

## ១០. វិសោធនកម្ម

កិច្ចសន្យានេះអាចកែសម្រួលបានក្នុងករណីអ្នករៀបចំកម្មវិធីយល់ថានៅមានចន្លោះខ្វះខាត ហើយមិនបំរើផលប្រយោជន៍ឱ្យអ្នកដាក់តាំងពិព័រណ៍ ឬធ្វើឱ្យខូចខាតដល់កម្មវិធី ។

## ១១. ភាពទទួលខុសត្រូវ និងហានិភ័យ

អ្នករៀបចំកម្មវិធី បុគ្គលិក ភ្នាក់ងារ ឬអ្នកតំណាងរបស់អ្នករៀបចំកម្មវិធីមិនទទួលខុសត្រូវចំពោះការបាក់បែក ឬការបាត់បង់ណាមួយ ដែលអាចកើតដោយសារអ្នកតាំងពិព័រណ៍ ឬបុគ្គលិករបស់អ្នកតាំងពិព័រណ៍ជាអ្នកបង្ករមូលហេតុណាមួយឡើយ។ ករណីប្រធានសក្តិ អ្នករៀបចំកម្មវិធីពុំត្រូវបានទទួលខុសត្រូវសម្រាប់ការពន្យាពេល ការខូចខាត ការបាត់បង់ ការបង្កើនតម្លៃ ឬលក្ខខ័ណ្ឌមិនអំណោយផលផ្សេងទៀតដែលកើតឡើងដោយសារមូលហេតុណាមួយដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់អ្នករៀបចំកម្មវិធីឡើយ។ រាល់សុវត្ថិភាពអគ្គីភ័យ សុខភាព និងច្បាប់ផ្សេងៗ បទបញ្ជា បទប្បញ្ញត្តិ និងកាតព្វកិច្ចផ្សេងណាមួយដែលបានដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា អង្គភាពនិងអាជ្ញាធរមានសមត្ថកិច្ចកម្ពុជានោះ អ្នកតាំងពិព័រណ៍ត្រូវតែអនុវត្តតាម។ អ្នករៀបចំកម្មវិធីនឹងខិតខំអស់ពីលទ្ធភាពសម្រាប់អញ្ជើញ និងទាក់ទាញអ្នកចូលទស្សនាណាដែលពាក់ព័ន្ធឱ្យមកចូលរួមក្នុងកម្មវិធីនេះ និងធ្វើការផ្សព្វផ្សាយគ្រប់វិធីសាស្ត្រឱ្យបានល្អនូវកម្មវិធីតាំងពិព័រណ៍នេះតាមរយៈព័ត៌មានផ្សេងៗ។

## ១២. ការតាំងផលិតផល

គ្រប់ក្រុមហ៊ុន (អ្នកចូលរួមតាំងពិព័រណ៍ ) ទាំងអស់មិនអាចយកផលិតផលក្លែងក្លាយ គ្មានគុណភាពហួសកាលកំណត់ នៃការប្រើប្រាស់ចូលមកធ្វើការដាក់តាំងបង្ហាញនៅក្នុងកម្មវិធីពិព័រណ៍នេះបានឡើយ ហើយមិនអនុញ្ញាតឱ្យមានការប្រកួតប្រជែងដណ្តើមអតិថិជន និងបង្ករឱ្យមានហេតុការណ៍មិនល្អក្នុងកម្មវិធីពិព័រណ៍បានឡើយ លុះត្រាណាអ្នកចូលរួមតាំងពិព័រណ៍នៅតែរឹងរូស និងបង្ករបញ្ហាផ្សេងៗធ្វើឱ្យមានការរំខានដល់កម្មវិធី

តាំងពិព័រណ៍នោះ អ្នកតាំងពិព័រណ៍ត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និងទទួលខុសត្រូវចំពោះសំណងផ្សេងៗ លើការខូចខាតកម្មវិធីទាំងមូល ។អ្នករៀបចំកម្មវិធីមិនអនុញ្ញាតឱ្យអ្នកចូលរួមតាំងពិព័រណ៍ទាំងអស់ជួលស្តង់ ដើម្បីដាក់តាំងតែផ្ទាំងរូបភាពប៉ុណ្ណោះទេ គឺតម្រូវឱ្យដាក់តាំងតែសម្ភារៈ ឬឧបករណ៍ ឬម៉ាស៊ីនជាក់ស្តែងនៅក្នុងកម្មវិធី ។

## ១៣. ការបង្ការអគ្គីភ័យ

អ្នកចូលរួមតាំងពិព័រណ៍ត្រូវតែគោរពតាមសេចក្តីណែនាំទាំងឡាយ ដែលបានផ្តល់ឱ្យដោយអាជ្ញាធរពាក់ព័ន្ធ ដើម្បីជៀសវាងហានីភ័យនៃអគ្គីភ័យ។ អ្នកតាំងពិព័រណ៍មិនត្រូវរៀបចំ ឬតុបតែងស្តង់ដោយប្រើប្រាស់សម្ភារៈដែលងាយឆេះឡើយ ។ ក្នុងព្រឹត្តិការណ៍ដែលមានអគ្គីភ័យដែលបង្កដោយសារតែសកម្មភាពរបស់អ្នកតាំងពិព័រណ៍នោះអ្នកតាំងពិព័រណ៍ត្រូវទទួលខុសត្រូវចំពោះការបាត់បង់ផ្សេងៗពីឧបទ្ទវហេតុនេះ ។

## ១៤. ការធានារ៉ាប់រង

អ្នកតាំងពិព័រណ៍ត្រូវតែធានារ៉ាប់រងនូវសម្ភារៈ បរិក្ខារ និងទ្រព្យសម្បត្តិរបស់ខ្លួនដែលបានយកមកដាក់តាំងពិព័រណ៍នូវការបាក់បែក អគ្គីភ័យ ចោរលួច ការរងរបួស ការស្លាប់ និងទ្រព្យសម្បត្តិរបស់ខ្លួន។ត្រូវចាក់សោរនៅពេលយប់ និងឃ្លាំមើលទូទៅនៃថ្ងៃតាំងពិព័រណ៍ខណៈពេលដែលមិនមានការតាំងបង្ហាញ។

## ១៥. អគ្គីសនី និងថាមពល

អ្នករៀបចំកម្មវិធីនឹងទទួលខុសត្រូវសម្រាប់ការផ្គត់ផ្គង់អគ្គីសនី ម៉ាស៊ីនត្រជាក់ អំពូលភ្លើង បំភ្លឺខាងក្នុង និង ខាងក្រៅសាលតាំងពិព័រណ៍ រួមជាមួយអគ្គីសនីប្រើប្រាស់ដោយអ្នកតាំងពិព័រណ៍ក្នុងអំឡុងពេលនៃការតាំងពិព័រណ៍ ។ ក្នុងករណីអ្នកតាំងពិព័រណ៍ត្រូវការកម្លាំងថាមពលអគ្គិសនីខ្លាំងលើសពីការផ្តល់ជូនដោយអ្នករៀបចំកម្មវិធីផ្តល់ជូននោះ អ្នកតាំងពិព័រណ៍ត្រូវបង់ប្រាក់លើការបន្ថែមថាមពលអគ្គិនី។

## ១៦. សន្តិសុខ

ការរៀបចំសន្តិសុខនឹងត្រូវបានផ្តល់ជូនជាចាំបាច់ដោយអ្នករៀបចំកម្មវិធី នៅតាមច្រកចូល-ចេញនៃបរិវេណសាលតាំងពិព័រណ៍ ក្នុងអំឡុងពេលដែលការតាំងពិព័រណ៍ត្រូវបានដល់ម៉ោងបិទ។ ទោះជាយ៉ាងណាក្តីអ្នកតាំងពិព័រណ៍គឺជា អ្នកទទួលខុសត្រូវទាំងស្រុងលើសម្ភារៈតាំងពិព័រណ៍ដោយផ្ទាល់របស់ពួកគេ និងត្រូវតែធានារ៉ាប់រងដោយខ្លួនឯង ពីការបាត់បង់ ឬខូចខាត ពីការលួច ឧបទ្ទវហេតុ ការបំផ្លិចបំផ្លាញ អគ្គីភ័យ ឬមូលហេតុបង្កផ្សេងៗ។ទ្រព្យសម្បត្តិទាំងអស់របស់អ្នកតាំងពិព័រណ៍ត្រូវបានយល់ថានៅតែស្ថិតក្នុងការយកចិត្តទុកដាក់ការថែរក្សា និងការគ្រប់គ្រងរបស់អ្នកតាំងពិព័រណ៍។

## ១៧. ការសហការ

អ្នកដាក់តាំងពិព័រណ៍ទាំងអស់ត្រូវសហការ ដោយរាយការណ៍ជូនសន្តិសុខ ឬអ្នករៀបចំកម្មវិធីក្នុង ក្នុងករណីមានសភាពការណ៍គួរឱ្យកត់សម្គាល់ក្នុងកម្មវិធី ។

## ១៨. ការបញ្ចប់កិច្ចសន្យា

អ្នករៀបចំកម្មវិធីអាចជូនដំណឹងជាលាយលក្ខអក្សរឱ្យទៅកាន់អ្នកតាំងពិព័រណ៍ ដើម្បីបញ្ចប់កិច្ចព្រមព្រៀងភ្លាម ប្រសិនបើអ្នកតាំងពិព័រណ៍ស្ថិតនៅក្នុងការបំពានច្បាប់ផ្សេងៗនៃគោលការណ៍របស់កិច្ចសន្យានេះ ឬអ្នករៀបចំកម្មវិធីមានហេតុផលសមរម្យផ្សេងដែលអាចជម្រុញចិត្តឱ្យបញ្ចប់កិច្ចសន្យាជាមួយនឹងអ្នកតាំង

ពិព័រណ៍។ បទបញ្ជា និងបទប្បញ្ញត្តិនៅក្នុងកិច្ចសន្យានេះត្រូវបានធ្វើវិសោធន៍កម្មដោយអ្នករៀបចំ ឬអ្នកគ្រប់គ្រងកម្មវិធី ពីពេលមួយទៅពេលមួយ ត្រូវបានអនុវត្តបន្ទាប់ពីមានការផ្តល់នូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកតាំងពិព័រណ៍រយៈពេលប្រាំពីរថ្ងៃមុន ។ បទប្បញ្ញត្តិនៃប្រការនេះ នឹងនៅតែជាធរមានពេញលេញ និងមានប្រសិទ្ធិភាព ទោះបីជាមានការបញ្ចប់ ឬផុតកំណត់នៃកិច្ចព្រមព្រៀងនេះដោយហេតុផលណាមួយក៏ដោយ។ដរាបណាមិនបានសរសេរជាលាយលក្ខណ៍អក្សរហើយបានចុះហត្ថលេខាដោយភាគីទាំងពីរនោះមិនមានការធ្វើវិសោធនកម្មលើកិច្ចសន្យានេះទេ ។

## ១៩. ការផ្ទេរភាពទទួលខុសត្រូវ និងព័ត៌មាន

អ្នកតាំងពិព័រណ៍មិនអាចផ្ទេរការទទួលខុសត្រូវដែលបានចងនៅក្នុងគោលការណ៍ និងលក្ខខ័ណ្ឌនៃកិច្ចសន្យាដែលមានការព្រមព្រៀងឱ្យទៅភាគីទី៣ ដើម្បីអនុវត្តក្នុងនាមរបស់ខ្លួនឡើយ។ រាល់ព័ត៌មានពាក់ព័ន្ធទៅនឹងការតាំងពិព័រណ៍ត្រូវតែបានផ្តល់ឱ្យ និងទទួលបានតែពីអ្នករៀបចំកម្មវិធីមួយគត់គឺជាសមាគមអ្នកសាងសង់កម្ពុជា ។

## ២០. ពេលវេលានៃកិច្ចសន្យា

កិច្ចសន្យានេះមានសុពលភាពចាប់ពីថ្ងៃដែលបានចុះហត្ថលេខាលើកិច្ចសន្យា។ ប៉ុន្តែការរុះរើស្តង់ សម្ភារៈ និងឧបករណ៍គឺមានសុពលភាពរហូតដល់ថ្ងៃបន្ទាប់នៃថ្ងៃបញ្ចប់កម្មវិធី វេលាម៉ោង ០៥ : ០០ ល្ងាច ។

## ២១. ឯកសារ

កិច្ចសន្យានេះគឺត្រូវបានធ្វើឡើងជាពីរច្បាប់ដូចគ្នាសុទ្ធសាធ ដែលភាគីនីមួយៗរក្សាទុកមួយច្បាប់។ ក្នុងករណី ដែលកិច្ចសន្យាប្រើតាមរយៈផ្ញើរអ៊ីម៉ែលវិញ អ្នករៀបចំកម្មវិធីនឹងត្រូវចុះហត្ថលេខា និងបោះត្រានៅលើកិច្ចសន្យា មុននឹងធ្វើការស្កេន និងផ្ញើរអ៊ីម៉ែលទៅកាន់អ្នកតាំងពិព័រណ៍។ បន្ទាប់ពីអ្នកតាំងពិព័រណ៍ទទួលបានកិច្ចសន្យានោះហើយ អ្នកតាំងពិព័រណ៍ត្រូវព្រីនកិច្ចសន្យានេះចេញ ហើយធ្វើការចុះហត្ថលេខា និងបោះត្រា រួចស្កេនវា និងផ្ញើរអ៊ីម៉ែលត្រលប់មកកាន់អ្នករៀបចំកម្មវិធីវិញ។ នោះភាគីនីមួយៗរក្សាទុកបាននូវកិច្ចសន្យាដែលមានចុះហត្ថលេខា និងត្រាពេញលេញ ។

**ចប់**